តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
សាលក្រម
លេខ ២៩ គ ចុះថ្ងៃទី ០៦
ខែ មីនា ឆ្នាំ ២០០៦
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥៧០ ចុះថ្ងៃទី ២១
ខែ កញ្ញា ឆ្នាំ ២០០៥

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### តាងនាមប្រជារាស្ត្រខ្មែរ
### តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ ៥៧០ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

-ឈ្មោះ **ស ខ** ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិសសរស្តម្ភ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប កំរិតវប្បធម៌គ្មាន សាសនាព្រះពុទ្ធ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិទន្លេស ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប របររកស៊ីធ្វើស្រែ ។ ប្រពន្ធឈ្មោះ **ស ស** មានកូន ០៣នាក់ ឪពុកឈ្មោះ **ស** (ស) ម្តាយឈ្មោះ **រ ខ** (រ) ទោសពីមុន *គ្មាន* ។

ចាប់ខ្លួនថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ។

ឃុំខ្លួនថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៥ ។

ត្រូវចោទពីបទ **ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិទន្លេស ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប កាលពីថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

មានលោកមេធាវី [redacted] **ទណ្ណារ៉ា** ជាអ្នកការពារសិទ្ធិជនជាប់ចោទ ។

ឈ្មោះ **ខ ច** ភេទស្រី អាយុ ៥៥ឆ្នាំ ជាដើមបណ្តឹងរដ្ឋប្បវេណី ជាតិខ្មែរ របររកស៊ីនៅផ្ទះ ទីលំនៅសព្វថ្ងៃនៅភូមិទន្លេស ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប ។

មានលោក [redacted] **ស៊ីន** ជាមេធាវីការពារសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណី ។

*សាលក្រមនេះចូលជាស្ថាពរនៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៦*
*ដោយពុំមានគូភាគីណាចូលមកប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*
*សៀមរាប.ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦*
***ក្រឡាបញ្ជី***
***ហត្ថលេខា និងត្រា***
[redacted]

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោងប្រហែល ៧:៣០នាទីយប់ឈ្មោះ **ស ខ** និង នាង **ថ ហ** ព្រមទាំងអ្នកភូមិ ៣,៤នាក់ទៀត បាននាំគ្នាផឹកស្រានៅផ្ទះនាង **យ ហ** ។ ពេលនោះឈ្មោះ **ស ខ** បានប្រើល្បិចបបួលនាង **ថ ហ** ទៅទិញស្រាតែ ០២នាក់ លុះដើរដល់អណ្តូងលូម៉ុំវាលត្រពាំងត្នោតក្នុងភូមិទន្លេស ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប ឃើញឱកាសស្ងាត់ល្អឈ្មោះ **ស ខ** បានចាប់ដៃស្តាំនាង **ថ ហ** ទាញផ្តួលទៅដីក្បាលកើយលើភ្លឺស្រែ ហើយយកដៃឆ្វេងខ្ទប់មាត់ ចំណែកដៃស្តាំវាចាប់ដៃស្តាំនាង **ថ ហ** ទាញឡើងទៅលើចាប់ភ្ជាប់ជាមួយសក់ក្បាល រួចយកជើងស្តាំថ្កក់ទាញសំពត់ទៅលើ យកលិង្គបញ្ចូលក្នុងប្រដាប់ភេទនាង **ថ ហ** ហើយធ្វើចលនារួមរ័ក្តរហូតបានសំរេច ពេលរំលោភរួចឈ្មោះ **ស ខ** ត្រូវជនរងគ្រោះគំរាមប្តឹង ហើយខ្លាចនាង **ថ ហ** ប្តឹងសមត្ថកិច្ចក៏ចាប់សក់ក្បាលនាង **ថ ហ** ទាញទម្លាក់ចូលក្នុងទឹកប្រឡាយជំរៅស្មើដោះ ជ្រមុជក្នុងទឹក ដោយវាឈរច្រកគាវពីលើយកជើងកៀបខ្លួននាង **ថ ហ** កុំអោយរើបានប្រហែល ០៥នាទី ទើបលែងដៃវិញ ធ្វើអោយនាង **ថ ហ** ស្លាប់មួយរំពេច ។ ឈ្មោះ **ស ខ** ត្រូវសមត្ថកិច្ចចាប់ខ្លួននៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ។

ក្នុងរឿងនេះឈ្មោះ **ខ ច** ជាម្តាយជនរងគ្រោះមិនប្តឹងទាមទារសំណងជម្ងឺចិត្តអ្វីទេ សូមឱ្យតុលាការផ្តន្ទាទោសឈ្មោះ **ស ខ** អោយបានធ្ងន់ធ្ងរកុំបីត្រាប្រណីឡើយ ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ **ស ខ** បានឆ្លើយថា នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោង ០៧ព្រឹក ខ្លួន និងឈ្មោះ **ថ ហ**, ឈ្មោះ **ន** ភេទស្រី, ឈ្មោះ **ស ស**, ឈ្មោះ **ត**, ឈ្មោះ **ន**, ឈ្មោះ **ព** និង ឈ្មោះ **ឝ** បាននាំគ្នាផឹកស្រាសជាមួយម្ចាស់ផ្ទះឈ្មោះ **យ ហ** ភេទស្រី រហូតដល់ម៉ោង ០១រសៀល, ឈ្មោះ **ស ស** បានទៅយកម៉ាញ៉េមកបើករាំលេងនៅកន្លែងផឹករហូតដល់ម៉ោង ០៧យប់ ។ ពេលនោះខ្លួនបាននាំនាង **ថ ហ** ទៅទិញស្រាតែ ០២នាក់ លុះដើរដល់អណ្តូងលូម៉ុំវាលត្រពាំងត្នោតក្នុងភូមិទន្លេស ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប ជាកន្លែងស្ងាត់ខ្លួនក៏ចាប់ដៃស្តាំនាង **ថ ហ** បំណងរំលោភសេពសន្ថវៈ ។ ខ្លួនក៏ទាញឈ្មោះ **ថ ហ** ផ្តួលទៅនឹងដីក្បាលកើយភ្លឺស្រែយកដៃឆ្វេងខ្ទប់មាត់ ឯដៃស្តាំចាប់ដៃស្តាំនាង **ថ ហ** ទាញទៅលើចាប់ភ្ជាប់ជាមួយសក់ក្បាល រួចយកជើងស្តាំថ្កក់ទាញសំពត់ភ្លីសេនាង **ថ ហ** ឡើងលើ ហើយចាប់លិង្គរបស់ខ្លួនបញ្ចូលក្នុងប្រដាប់ភេទនាង **ថ ហ** រួចធ្វើចលនារួមរ័ករហូតបានសំរេចទើបឈប់ ។ ពេលនោះខ្លួនប្រុងដើរចេញទៅហើយ តែពួនាង **ថ ហ** និយាយថា ស្អែកនាងនឹងប្តឹងនគរបាលឱ្យចាប់ខ្លួន ។ ដោយខ្លាចបែកការ ខ្លួនក៏ចាប់សក់ក្បាលនាង **ថ ហ** ទាញទម្លាក់ចូលក្នុងទឹកប្រឡាយជំរៅស្មើដោះ ហើយជ្រមុជនាង **ថ ហ** ក្នុងទឹកដោយឈរច្រកគាវពីលើយកជើងកៀបខ្លួននាង **ថ ហ** កុំអោយរើបានប្រហែល ០៥នាទី ទើបព្រលែងដៃវិញ ហើយឡើងទៅទិញស្រា ។ ដល់វិលមកវិញខ្លួនបានលើកនាងដាក់លើគោក ក្រែងនាងនៅរស់ ។ លុះទិញស្រាបានយកមកផឹកនៅផ្ទះឈ្មោះ **យ ហ** ទៀត រួចទើបបែកគ្នាទៅផ្ទះរៀង១ខ្លួន ។

ឈ្មោះ **ខ ច** ជាម្តាយជនរងគ្រោះបានឆ្លើយថា នៅថ្ងៃពេញបូរមី ខែភទ្របទ ឆ្នាំរកា " ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៥ " កូនស្រីខ្លួនឈ្មោះ **ថ ហ** បានដើរលេង ផ្ទះបងប្អូនជាមួយឈ្មោះ **ព ន** ភេទស្រី នៅភូមិជាមួយគ្នា ។ រហូតដល់ម៉ោងប្រហែល ០៧យប់ ទើបមានឈ្មោះ **អ** និង ឈ្មោះ **អ** "មិនស្គាល់ត្រកូល" បានសួររកកូនខ្លួនឈ្មោះ **ថ ហ** ហើយមានឈ្មោះ **ខ** ឈរមុខជណ្តើរខាងកើតផ្ទះស្លៀកខោស្លឹបអត់ពាក់អាវមកជាមួយដែរ ពេលនោះ

ខ្លួនឆ្លើយមិនទាន់ឃើញវាមកផ្ទះទេ រួចឈ្មោះ ខ និយាយថា អ៊ីឯងកុំភ័យព្រឹកនេះដឹងហើយ ឮដូច្នេះខ្លួនបានចង្អុលមុខឈ្មោះ ខ និយាយថា អាឯងសម្លាប់កូនអញឬ ? តែវាមិនឆ្លើយតបទេបែរជាដើរតាមផ្លូវចេញបាត់ទៅ ។ ថាឈ្មោះ ខ មកសួររកនាង ឋ ហ្ម មួយភ្លែតនោះ ០២ដង រួចវាដើរទៅផ្ទះនាង ព ន ដែលនៅខាងលិចជាប់របងផ្ទះខ្លួនបាត់ទៅ លុះព្រឹកឡើងម៉ោងប្រហែល ០៦ព្រឹក កូនស្រីខ្លួនឈ្មោះ ឋ រ រត់យំមកប្រាប់ថា នាង ឋ ហ ស្លាប់ហើយ ឮដូច្នេះខ្លួនក៏ទៅមើលឃើញនាង ឋ ហ ត្រូវស្លាប់ហើយមានសមត្ថកិច្ចឱ្យគេស្រង់សាកសពពីទឹកប្រឡាយកន្លែងជ្រៅ មកទុកត្រង់ទឹករាក់ដោយសាកសពមានជាំភ្លៅទាំងសងខាងលើមុខមានស្នាមក្រចៅដាច់លើស្បែកជាច្រើនកន្លែងឯកទន់ល្មៀកបាត់ខោស្លីបដែលស្លៀកជាប់នឹងខ្លួន រួចខ្លួនបានយកសពនាង ឋ ហ ទៅធ្វើបុណ្យបូជារួចរាល់អស់ហើយ ។

ក្នុងរឿងនេះខ្លួនមិនប្តឹងទាមទារសំណងជម្ងឺចិត្តអ្វីទេ តែសូមតុលាការដាក់គុកជនជាប់ចោទអស់មួយជីវិតកុំបីត្រាប្រណីឡើយ ។

សាក្សីឈ្មោះ ឃ ហ បានឆ្លើយថា នៅថ្ងៃពេញបូរមី ខែភទ្របទ ឆ្នាំរកា " ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៥ " វេលាម៉ោងប្រហែល ០៨ព្រឹក ខ្លួនបានទៅទិញស្មាច់ជ្រូកនៅតូបឈ្មោះ អ បានឃើញឈ្មោះ ន និង ឈ្មោះ ហ ភេទស្រី កំពុងផឹកស្រានៅទីនោះ ហើយឈ្មោះ ន និង ឈ្មោះ ហ ទិញស្រាស ០១លីត្រដាក់ស្បោងដើរមកផ្ទះរបស់ខ្លួនមុន ហើយខ្លួនដើរមកជាក្រោយ ដល់ផ្ទះស្រុះសាច់ជ្រូកក្លែមស្រាជាមួយឈ្មោះ ន, ឈ្មោះ ហ ឈ្មោះ ខ, ឈ្មោះ ស និងឈ្មោះ ព រហូតដល់ម៉ោង ០៧យប់ ។ ពេលនោះខ្លួនឃើញឈ្មោះ ខ ទៅរកទិញស្រា ហើយនិយាយនាំនាង ឋ ហ ថា មកអញជូនហ្វែងទៅផ្ទះ ហើយនាង ឋ ហ ក៏ទៅជាមួយមានស្លៀកសំពត់ភ្លីសេ ពណ៌ក្រហម ពាក់អាវដៃខ្លីពណ៌ផ្កាឈូក ។ ចំណែកឈ្មោះ ខ ស្រាតខោជើងវែងក្រវ៉ាតចង្កេះ ស្លៀកតែខោស្លីបប៉ុណ្ណោះ រំលងប្រហែលកន្លះម៉ោងទើបឃើញឈ្មោះ ខ មកវិញ ហើយឈ្មោះ ន សួររកនាង ឋ ហ ឈ្មោះ ខ ឆ្លើយថា អញជូនមី ហ ដល់ផ្ទះហើយ រួចនាង ន លើកកូនពរឱ្យឈ្មោះ ព ជូនទៅផ្ទះដែរ ។ លុះដល់ម៉ោងប្រហែល ១០យប់ឈ្មោះ ខ និយាយប្រាប់ខ្លួនថា ស្រណោះមី ហ ណាស់មិនដឹងឡើងម៉ូតូអ្នកណាទេ ខ្លាចតែគេវាយងាប់ រួចវាក៏ចុះទៅផ្ទះទៅ ។

តាមចម្លើយរបស់ឈ្មោះ ស សុ បានឆ្លើយថា នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោងប្រហែល ០៧ព្រឹក ខ្លួនបានផឹកស្រាជាមួយឈ្មោះ ស ខ និង ឈ្មោះ ព នៅផ្ទះម្តាយក្មេកឈ្មោះ ឃ ហ ។ រហូតដល់ម៉ោង ១១ថ្ងៃត្រង់ ទើបឃើញឈ្មោះ ឋ ហ និង ឈ្មោះ ន ភេទស្រី ដើរមកដល់ក៏ចូលផឹកស្រាជាមួយរហូតដល់ម៉ោងប្រហែល ៧:៣០នាទីយប់ ឈ្មោះ ស ខ បាននិយាយប្រាប់ខ្លួនថា វាបបួលនាង ឋ ហ ទៅទិញស្រា ខ្លួនឆ្លើយថាស្រេចតែហ្វែងទៅ ឈ្មោះ ន បានឮក៏សុំទៅដែរ តែឈ្មោះ ស ខ មិនឱ្យទៅទេ ហើយវាទៅទិញស្រាតែ ០២នាក់នាង ឋ ហ ប្រហែលជា ២៥នាទី ទើបឃើញឈ្មោះ ស ខ ត្រឡប់មកវិញមានកាន់ស្រាមួយដបផង តែមិនឃើញនាង ឋ ហ មកជាមួយទេ ។ ពេលនោះឈ្មោះ ស ខ បានខ្សឹបប្រាប់ខ្លួនថា វារំលោភនាង ឋ ហ រួចហើយ ឮដូច្នេះខ្លួនមិននិយាយតបទេ តែឈ្មោះ ន បានសួរឈ្មោះ ស ខ រកនាង ឋ ហ ត្រូវវាប្រាប់ថា នាង ឋ ហ ទៅផ្ទះបាត់ហើយ ឈ្មោះ ន បានឱ្យឈ្មោះ ព ជូនមកផ្ទះ មួយសន្ទុះមានតាឈ្មោះ ជ បានដេញខ្លួនឱ្យទៅតាមឈ្មោះ ព មកផ្ទះវិញខ្លួន និង ឈ្មោះ ស ខ បានទៅតាមហៅឈ្មោះ ព ដល់ផ្ទះឈ្មោះ ន តែត្រូវឈ្មោះ ព ឱ្យមកផ្ទះមុន ។ ថា ពួកខ្លួនបានឈៀងចូលទៅផ្ទះយាយឈ្មោះ ច សួររកនាង ឋ ហ គាត់ប្រាប់ថា មិនឃើញទេ ស្រាប់តែឈ្មោះ ស ខ និយាយថា បើមិនឃើញទេ ចាំព្រឹកដឹងហើយ រួចនាំគ្នាទៅផ្ទះម្តាយក្មេកខ្លួនវិញទៅ ។

តាមចម្លើយរបស់ឈ្មោះ ព ន បានឆ្លើយថា នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៥ ម៉ោងប្រហែល ៦:៣០ នាទីព្រឹក ខ្លួនបានទៅទិញសាច់ជ្រូកនៅតូបឈ្មោះ អ ភេទស្រី ក៏ជួបនិងឈ្មោះ ឋ ហ, ឈ្មោះ ហ កំពុងផឹកស្រា

នៅទីនោះ ខ្លួនក៏ចូលទៅផឹកជាមួយគេ ហើយមានឈ្មោះ ឃ ហ ភេទស្រី មកដល់ខ្លួនឱ្យស្រាគាត់ផឹក ០១កែវ ហើយនាំគ្នាទៅផឹកនៅផ្ទះគាត់ទៀត ។ នៅទីនោះមានមនុស្សប្រុសឈ្មោះ ស ខ. ឈ្មោះ ស និង ឈ្មោះ ព ផឹកជាមួយដែររហូតដល់ម៉ោង ៧:៣០នាទីយប់ឈ្មោះ ស ខ បានជូននាង ឌ ហ ទៅផ្ទះប្រហែលកន្លះម៉ោងទើបឃើញឈ្មោះ ស ខ ត្រឡប់ទៅវិញមានកាន់ស្រា ១ដបផង ខ្លួនបានសួររកនាង ឌ ហ ត្រូវឈ្មោះ ស ខ ប្រាប់ថា វាទៅផ្ទះហើយអញជូនដល់ថ្នល់ទៅផ្ទះវា ។ ឮដូច្នេះខ្លួនក៏ឱ្យឈ្មោះ ព ជូនមកផ្ទះដែរ ក្រោយមកមានឈ្មោះ ស ខ និង ឈ្មោះ ស ដើរមកឈរនៅមុខផ្ទះខ្លួនមិនបានហៅឱ្យឡើងលើផ្ទះទេ ពួកគេក៏ត្រឡប់ទៅវិញចូលផ្ទះយាយ ច ម្ដាយនាង ឌ ហ សួររកនាង ឌ ហ តែត្រូវយាយ ច ប្រាប់ថា មិនឃើញមកផ្ទះទេ ពេលនោះឈ្មោះ ស ខ បាននិយាយថា ចាំតែព្រឹកនឹងដឹងហើយយាយ ច បានតបថា បើកូនអញស្លាប់គ្មានអ្នកឯណាក្រៅពីអាឯងសម្លាប់ទេ ហើយពួកគេក៏បែកគ្នាទៅផ្ទះរៀង១ខ្លួនទៅ ។

## តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានទោសថា

ឆ្លងតាមការសួរដេញដោលក្នុងសវនាការនេះឃើញថា ជនជាប់ចោទបានឆ្លើយសារភាពនូវទោសកំហុសខ្លួនថា ពិតជាបានរំលោភសេពសន្ថវៈ ហើយទាញទម្លាក់ជនរងគ្រោះជ្រមុជក្នុងទឹកជ្រៅស្ទើដោះឱ្យស្លាប់ ព្រោះខ្លាចជនរងគ្រោះប្ដឹងសមត្ថកិច្ច ដែលស៊ីសង្វាក់នឹងចម្លើយសាក្សីជាច្រើនថា បានឃើញឈ្មោះ ស ខ បបួលនាង ឌ ហ មកទិញស្រាតែ ០២នាក់នៅពេលយប់ ហើយឃើញ ស ខ ត្រឡប់ទៅវិញតែម្នាក់ឯង ហើយទៅប្រាប់ឈ្មោះ ស ស ថា វាបានរំលោភសេពសន្ថវៈលើនាង ឌ ហ នៅយប់នោះមែន ។ ដូច្នេះសូមតុលាការតម្កល់ការចោទប្រកាន់លើឈ្មោះ ស ខ ពីបទឃាតកម្មគិតទុកជាមុន តាមដីកាសន្និដ្ឋានស្ថាពរលេខ ២២២ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ រក្សាទុកជាបានការដដែល ។

ហេតុនេះសូមតុលាការពិចារណា និង សំរេចតាមច្បាប់ចុះ ។

មេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា ក្នុងរឿងនេះកូនក្ដីខ្លួនបានឆ្លើយសារភាពពីទោសកំហុសដែលបានប្រព្រឹត្ត ជូនតុលាការដោយស្មោះត្រង់អស់ហើយ តែសូមតុលាការពិចារណាពីភាពល្ងង់ខ្លៅ ហើយព្រោះតែស្រវឹងស្រាទើបធ្លោយគំនិតប្រព្រឹត្តអំពើបែបនេះជាលើកដំបូង ។

ហេតុនេះសូមតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួនដោយអនុគ្រោះ ។

មេធាវីការពារសិទ្ធិម្ដាយជនរងគ្រោះបានធ្វើសេចក្ដីសន្និដ្ឋានថា ឆ្លងតាមសវនាការនេះ ជនជាប់ចោទបានឆ្លើយសារភាពពីសកម្មភាពឃោរឃៅព្រៃផ្សៃរបស់វា ដែលប្រើល្បិចលួងលោមជនរងគ្រោះថា នាំទៅទិញស្រាមកផឹកទាំងអស់គ្នា លុះដល់កន្លែងស្ងាត់ក៏ធ្វើតាមគំនិត ដែលគិតជាមុនដោយចាប់បង្ខំរំលោភសេពសន្ថវៈលើជនរងគ្រោះរហូតបានសំរេច ហើយទាញទម្លាក់ទឹកជ្រៅចាប់សក់ជ្រមុជក្បាលជនរងគ្រោះក្នុងទឹកដាច់ខ្យល់ស្លាប់មួយរំពេច ក្នុងន័យប្រមាថម៉ាក់ងាយស្ត្រីដូចសត្វធាតុ ចាត់ទុកស្ត្រីជាឧបករណ៍គ្រាន់តែបំរើសេចក្ដីសប្បាយរបស់ខ្លួនរួចសម្លាប់ចោលមិនគិតក្រែងរអាបន្តិចសោះ ។

ហេតុនេះសូមតុលាការមេត្តាដាក់ទោសជនជាប់ចោទឱ្យបានធ្ងន់ធ្ងរកុំបីត្រាប្រណីឡើយ ។

ជនជាប់ចោទបាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនដោយអនុគ្រោះផងចុះ ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយម្ដាយជនរងគ្រោះ

-ក្រោយពីបានស្តាប់ការអានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ</u>

## <u>យល់ឃើញថា</u>

-កាលពីថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោង ៧:៣០នាទីយប់ ឈ្មោះ **ស ខ** ឃើញនាង **ឡ ម** ស្រវឹងខ្លាំងបានប្រើល្បិចនិយាយកុហកថា នាំទៅទិញស្រាមកផឹកទាំងអស់គ្នាទៀត ។ លុះដើរដល់កន្លែងស្ងាត់បានចាប់ជនរងគ្រោះផ្តួលទៅដី ប្រើកំលាំងសង្កត់ខ្លួនប្រាណបង្ខំរំលោភសេពសន្ថវៈរហូតបានសំរេច និង ដោយខ្លាចគេដឹងពីទង្វើខុសច្បាប់របស់ខ្លួន ក៏ទាញជនរងគ្រោះទម្លាក់ទឹកប្រឡាយជំរៅស្មើដោះ ហើយចាប់ជិះពីលើសង្កត់ទៅក្នុងទឹកធ្វើអោយជនរងគ្រោះលង់ទឹកដាច់ខ្យល់ស្លាប់ ទុកចោលនៅក្នុងទឹក ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានថែង និង ផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

-បើពិនិត្យឱ្យជិតដល់ទៅឃើញថា ជនជាប់ចោទមិនត្រឹមតែបំពារបំពានលើសិទ្ធិរូមភេទ ថែមទាំងមានចិត្តឃោរឃៅសម្លាប់ជនរងគ្រោះ ដើម្បីបំបិទមាត់ទៀត ។

-ឈ្មោះ **ទ ច** ជាម្តាយជនរងគ្រោះមិនប្តឹងទាមទារសំណងជម្ងឺចិត្តអ្វីទេ តុលាការមិនពិចារណាដល់បញ្ហានេះឡើយ ។

## <u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសឈ្មោះ **ស ខ** ដាក់គុកកំណត់ ២៥ឆ្នាំ ( ម្ភៃប្រាំឆ្នាំ ) គិតពីថ្ងៃឃុំខ្លួន ។

ពីបទ **<u>ឃាតកម្មគិតទុកជាមុន</u>** តាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ប្រព្រឹត្តនៅភូមិទន្លេស ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប កាលពី ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៥ ។

២-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ០២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ**

**ហត្ថលេខា និង ត្រា**

[redacted]

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា និង ត្រា**

[redacted]